គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ទស្សនៈវិស័យ ៖ សង្គមប្រជាធិបតេយ្យ ដែលការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ដែលប្រកបដោយគុណភាពផ្តល់ប្រយោជន៍ដល់ប្រជាជន

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## របាយការណ៍សង្ខេបនៃការឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី១ នៃនីតិកាលទី៥

ចាប់ពីខែសីហា ឆ្នាំ២០១៤ ការប្រព្រឹត្តទៅរបស់រដ្ឋសភាមានទម្រង់ពេញលេញ ហើយក៏មានការបែងចែកអំណាចក្នុងរដ្ឋសភារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ និងការទទួលស្គាល់គណៈបក្សប្រឆាំងដែលមានអាសនៈក្នុងរដ្ឋសភា។ ការសង្កេតឃើញថា មានសកម្មភាពរបស់រដ្ឋសភា និងតំណាងរាស្ត្រល្អប្រសើរជាងមុនច្រើន ទាក់ទងការបំពេញតួនាទីរបស់គណៈកម្មការជំនាញក្នុងការសួរដេញដោលសមាជិករាជរដ្ឋាភិបាល។ ជាមួយគ្នានេះ តួនាទីរបស់តំណាងរាស្ត្រក្នុងកិច្ចអន្តរាគមន៍ និងការចុះមូលដ្ឋាន ឬការចុះទៅមណ្ឌលក៏មានការកើនឡើងផងដែរ។ ខាងក្រោមជារបាយការណ៍រកឃើញចំណុចសំខាន់ៗ និងផ្តល់អនុសាសន៍។

**ការខ្វះតម្លាភាព និងខ្វះនីតិវិធីនៃការផ្លាស់ប្តូរតំណាងរាស្ត្រ ការផ្លាស់ប្តូរបញ្ជីគណបក្សដោយគណបក្សនយោបាយ:** ច្បាប់ក៏ដូចជានីតិវិធីបោះឆ្នោត មិនបានចង្អុលបង្ហាញ ឬបញ្ញត្តិអំពីនីតិវិធីនៃការផ្លាស់ប្តូរបេក្ខជនជាប់ឆ្នោតនៅដំណាក់កាលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រនោះទេ ដូច្នេះការអនុវត្តន៍របស់ គ.ជ.ប កន្លងមក ក្នុងការប្រកាសដោះដូរបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ជាការអនុវត្តន៍ដោយគ្មានតម្លាភាពដោយ «សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា» ដែលសាធារណជន ម្ចាស់ឆ្នោតមណ្ឌលនីមួយៗមិនទទួលបានព័ត៌មាន។

គណបក្សនយោបាយ តែងតែដក ដាក់ និងធ្វើការផ្លាស់ប្តូរតំណាងរាស្ត្រនៅក្នុងបញ្ជីរបស់គណបក្សនយោបាយ និងថ្នាក់ដឹកនាំរដ្ឋសភា (អនុប្រធានរដ្ឋសភា) ធ្វើឡើង ដោយមិនមានតម្លាភាព និងមិនមាននីតិវិធីច្បាស់លាស់។ ការខ្វះតម្លាភាព បាននាំមកនូវការធ្លាក់ចុះសិទ្ធិ និងអំណាចអ្នកតំណាងរាស្ត្រ តែបានផ្តល់អំណាចយ៉ាងធំធេងដល់គណបក្សនយោបាយ (ថ្នាក់ដឹកនាំ)។

ករណីនេះបានកើតឡើងចំពោះគណបក្សប្រជាជនកម្ពុជា នៅដំណាក់កាល គ.ជ.ប ប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រដូចជាករណីលោក ឈាន វុន និងលោក ហ៊ុន ម៉ានី និងករណីដោះដូរលោក សម រង្ស៊ី ជំនួសលោក គួយ ប៊ុនរឿន ជាអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមនៃគណបក្សសង្គ្រោះជាតិ។

**ការប្រព្រឹត្តទៅរបស់រដ្ឋសភា និងសកម្មភាពអ្នកតំណាងរាស្ត្រ រួមទាំងការប្រជុំពេញអង្គរដ្ឋសភាក្នុងដំណាក់កាលគ្មាននីត្យានុកូលៈ** ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានរៀបចំការប្រព្រឹត្តទៅនៃរដ្ឋសភា និងរៀបចំការដឹកនាំក្នុងរដ្ឋសភាទាំងអស់ ទាំងប្រធាន អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការជំនាញទាំង៩។

នៅក្នុងកិច្ចប្រជុំរដ្ឋសភាដំបូង កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ មានតែបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន៦៨រូប មកពីគណបក្សប្រជាជនកម្ពុជាទេ បានចូលរួមក្នុងកិច្ចប្រជុំដំបូងនោះ ដោយមិនមានវត្តមានបេក្ខជនជាប់

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

ឆ្នោតជាតំណាងរាស្ត្រចំនួន៥៥រូបរបស់គណបក្សសង្គ្រោះជាតិ។ ក្នុងដំណើរការនេះ បេក្ខជនជាប់ឆ្នោត ចំនួន៦៨រូបមកពីគណបក្សប្រជាជនកម្ពុជា បានក្លាយជាសមាជិកជាតំណាងរាស្ត្រ ខណៈពេលដែលបេក្ខជនជាប់ឆ្នោត៥៥រូបរបស់គណបក្សសង្គ្រោះជាតិ មិនទាន់ក្លាយជាសមាជិកតំណាងរាស្ត្រនៅឡើយទេ ដែលមិនស្របមាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញចែងថា រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប។

រដ្ឋសភា ត្រូវបានបង្កើតដោយគ្មានការចូលរួមពីពហុបក្ស ក្នុងការឆ្លើយតបនឹងមាត្រា០១ និងមាត្រា០៨ នៃរដ្ឋធម្មនុញ្ញដែលចែងថា ព្រះរាជាណាចក្រកម្ពុជាតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ក្នុងរយៈពេលនោះដែរ សេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន ត្រូវបានអនុម័តស្ទើរតែមិនមានការពិភាក្សាពីសំណាក់អ្នកតំណាងរាស្ត្រនៅក្នុងកិច្ចប្រជុំរបស់រដ្ឋសភា។ ជាក់ស្តែង នៅក្នុងកិច្ចប្រជុំរដ្ឋសភាចាប់ពីខែមីនា ដល់ខែមិថុនា ឆ្នាំ២០១៤ ការសង្កេតឃើញថា ក្នុងចំណោមសេចក្តីព្រាងច្បាប់ចំនួន៨[1] មានតែសេចក្តីព្រាងច្បាប់ចំនួន២[2] ត្រូវបានអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិ ហើយការបញ្ចេញមតិនោះបានត្រឹមតែ១មាត្រា ក្នុង១ជំពូកតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ រដ្ឋសភាក៏បានអនុម័តច្បាប់ចំនួន៣ ទាក់ទងវិស័យតុលាការ។ រាជរដ្ឋាភិបាល និងរដ្ឋសភាឯកបក្សមិនបានផ្សព្វផ្សាយ និងបើកឱ្យសាធារណជនបានពិនិត្យ និងចូលរួមផ្តល់យោបល់ មុននឹងបញ្ជូនទៅដល់រដ្ឋសភាពិភាក្សា និងអនុម័ត។ម្យ៉ាងទៀត ការអនុម័តនោះមិនមានការចូលរួមពីក្រុមតំណាងរាស្ត្រគណបក្សប្រឆាំង។

**ការប្រព្រឹត្តទៅនៃការប្រជុំពេញអង្គរដ្ឋសភា ដែលមានទម្រង់ពេញលេញពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ:** ចាប់ពីខែសីហា ឆ្នាំ២០១៤ រចនាសម្ព័ន្ធដឹកនាំនៃរដ្ឋសភា ប្រធាន អនុប្រធានទាំង២នៃរដ្ឋសភា រួមទាំងគណៈកម្មការអចិន្ត្រៃយ៍ ប្រធាន និងអនុប្រធានទាំង១០ នៃគណៈកម្មការជំនាញនានារបស់រដ្ឋសភា គឺត្រូវបានបង្កើត និងបែងចែកអំណាច ក្នុងចំណោមគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា។ ប្រធាន និងអនុប្រធានទី២នៃរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ហើយអនុប្រធានទី១ ដឹកនាំដោយគណបក្សសង្គ្រោះជាតិ។ គណៈកម្មការជំនាញដែលគណបក្សប្រជាជនកម្ពុជាធ្វើជាប្រធាន និងជាលេខាធិការនោះ រួមមាន គណៈកម្មការទី២ គណៈកម្មការទី៤ គណៈកម្មការទី៥ គណៈកម្មការទី៦ និងគណៈកម្មការទី៩។ ចំណែកឯគណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិធ្វើជាប្រធាន និងជាលេខាធិការរួមមានដូចជា គណៈកម្មការទី១ គណៈកម្មការទី៣ គណៈកម្មការទី៧ គណៈកម្មការទី៨ និងគណៈកម្មការទី១០។

ក្នុងរយៈពេលពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០១៤ ការប្រជុំពេញអង្គរដ្ឋសភាមានចំនួន១១លើក សេចក្តីព្រាង/សេចក្តីស្នើច្បាប់ចំនួន៧ ត្រូវបានរដ្ឋសភាយកមកពិភាក្សា និងអនុម័ត ក្នុងនោះរួមមាន វិសោធនកម្មច្បាប់ចំនួន៣ច្បាប់

---

[1] ១.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃធម្មនុញ្ញអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះ, ២.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍, ៣.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ, ៤.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការសុំចូលរួមជាភាគីហត្ថលេខីរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងពិធីសារនៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិស្តីពីសាមញ្ញកម្ម និងសុខដុមនីយកម្មនីតិវិធីគយ, ៥.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យរដ្ឋប្បវេណី រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម, ៦.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម, ៧.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និង៨.ច្បាប់ស្តីពីការធានារ៉ាប់រង។

[2] ១.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និង២.ច្បាប់ស្តីពីការធានារ៉ាប់រង។

(វិសោធនកម្មរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភាជាដើម) អនុម័តសេចក្តីព្រាងច្បាប់ចំនួន២ច្បាប់ (ច្បាប់ស្តីពីថវិកាជាតិគ្រប់គ្រងឆ្នាំ២០១៥ និងច្បាប់ស្តីពីចរាចរផ្លូវគោក) និងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួន២។

សេចក្តីព្រាងច្បាប់ស្តីពីថវិកាជាតិគ្រប់គ្រងឆ្នាំ២០១៥ ត្រូវបានរដ្ឋសភាយកមកពិភាក្សា និងអនុម័ត ដោយប្រើប្រាស់រយៈពេលត្រឹមតែ១ថ្ងៃប៉ុណ្ណោះ។ ច្បាប់នេះត្រូវបានអនុម័ត ប៉ុន្តែតំណាងរាស្ត្រគណបក្សប្រឆាំងមិនបានគាំទ្រនោះទេ។ តំណាងរាស្ត្រគណបក្សប្រឆាំងលើកមូលហេតុថា ច្បាប់នេះត្រូវបញ្ជូនដល់ដៃអ្នកតំណាងរាស្ត្រមានរយៈពេលខ្លីពេក ហើយច្បាប់នេះនៅមានភាពខ្វះចន្លោះច្រើន ដោយសារតែឯកសារដែលអ្នកតំណាងរាស្ត្របានស្នើសុំមួយចំនួន មិនត្រូវបានផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះទេ។

ប្រហាក់ប្រហែលនីតិកាលទី៤ នៃរដ្ឋសភា ការលំបាកក្នុងការទំនាក់ទំនងសាកសួរ និងទទួលព័ត៌មានផ្លូវការពីអគ្គលេខាធិការដ្ឋានរបស់រដ្ឋសភា ជាមួយតំណាងរាស្ត្រ ពិសេសតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។ ខុទ្ទកាល័យ និងអគ្គលេខាធិការដ្ឋាន ដែលគ្រប់គ្រងដោយគណបក្សសង្គ្រោះជាតិ គឺមានការងាយស្រួលក្នុងការទំនាក់ទំនងជាមួយតំណាងរាស្ត្ររបស់ខ្លួន។

**ការប្រព្រឹត្តទៅរបស់គណៈកម្មការជំនាញនៃរដ្ឋសភាៈ** បើធ្វើការប្រៀបធៀបក្នុងរយៈពេលដូចគ្នា (រយៈពេល១ឆ្នាំ) នៅនឹងសកម្មភាពនៃគណៈកម្មការជំនាញនៃរដ្ឋសភាឃើញថា ខុមហ្វ្រែលមិនដែលបានទទួលព័ត៌មានណាមួយពាក់ព័ន្ធទៅនឹងការកោះអញ្ជើញតំណាងរដ្ឋាភិបាល មកសាកសួរនៅក្នុងគណៈកម្មការឡើយ។ ការប្រជុំក្នុងគណៈកម្មការជំនាញជាមួយតំណាងរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៤ ធ្វើឡើងទាក់ទងតែទៅនឹងការពិភាក្សាលើសេចក្តីព្រាងច្បាប់ ដែលរាជរដ្ឋាភិបាលបញ្ជូនមករដ្ឋសភាធ្វើការពិភាក្សា និងអនុម័ត។

ដូចគ្នាដែរ ក្នុងរយៈពេលដែលរដ្ឋសភាឯកបក្សដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ ក្រុមតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា បានកោះអញ្ជើញតំណាងរាជរដ្ឋាភិបាលចំនួន១រូប មកបំភ្លឺផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា។

បន្ទាប់ពីមានការបែងចែកអំណាច រវាងគណបក្សទទួលអាសនៈក្នុងរដ្ឋសភានីតិកាលទី៥នេះ គណៈកម្មការជំនាញមួយចំនួន ដឹកនាំដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ចាប់ពីអំឡុងខែសីហា ដល់ខែធ្នូ ឆ្នាំ២០១៤ ការសង្កេតឃើញថា គណៈកម្មការជំនាញនោះការមមាញឹកក្នុងកោះហៅរដ្ឋមន្ត្រី មកសួរដេញដោល បំភ្លឺផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញរបស់ខ្លួន។ ការកោះអញ្ជើញនោះរួមមាន រដ្ឋមន្ត្រី អភិបាលខេត្ត និងអង្គការសង្គមស៊ីវិលសរុបចំនួន ១៣លើក[3]។

---

[3] គណៈកម្មការទី១ ដឹកនាំដោយលោក អេង ឆៃអ៊ាង បានធ្វើសកម្មភាពសកម្ម ក្នុងការទទួលយកញត្តិពីពលករ កម្មករ ប្រជាពលរដ្ឋដែលមានបញ្ហាទំនាស់ដីធ្លី និងបានកោះអញ្ជើញអភិបាលនៃគណៈអភិបាលខេត្តចំនួន២រូបគឺ អភិបាលនៃគណៈអភិបាលខេត្តកោះកុង និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។ ដោយឡែក គណៈកម្មការទី៣ ដឹកនាំដោយលោក ប៉ុល ហំម បានកោះអញ្ជើញតំណាងរាជរដ្ឋាភិបាលចំនួន៣រូប មកបំភ្លឺផ្ទាល់មាត់នៅក្នុងគណៈកម្មការរបស់ខ្លួនរួមមាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីធនធានទឹក និងរដ្ឋមន្ត្រីក្រសួងកសិកម្ម។ ជាមួយគ្នានេះ គណៈកម្មការទី៧ ដឹកនាំដោយលោក យ៉ែម បុញ្ញឫទ្ធិ បានកោះហៅរដ្ឋមន្ត្រីចំនួន៤រូប រួមមាន រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ គណៈកម្មការទី៨ ដឹកនាំដោយលោកស្រី កែ សុវណ្ណរតន៍ បានកោះអញ្ជើញរដ្ឋមន្ត្រី៣រូប រួមមានរដ្ឋមន្ត្រីក្រសួងការងារ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។ ចុងក្រោយ គណៈកម្មការទី១០ ដឹកនាំដោយលោក ហូរ វ៉ាន់ បានកោះអញ្ជើញលោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និង អង្គការតម្លាភាពកម្ពុជាមកបំភ្លឺផ្ទាល់មាត់នៅក្នុងគណៈកម្មការផងដែរ។

ប្រធានរដ្ឋសភា (គណបក្សប្រជាជនកម្ពុជា) បានចេញបទបញ្ជាជាឯកត្តភូត ឬសារាចរណែនាំស្តីពីបែបបទការងាររបស់គណៈកម្មការនានានៃរដ្ឋសភា ហាមមិនឱ្យគណៈកម្មការអញ្ជើញសង្គមស៊ីវិល ឬអ្នកសារព័ត៌មានមកសង្កេតការណ៍។ ដូចនេះហើយការសួរដេញដោលពីគណៈកម្មការជំនាញទៅរដ្ឋមន្ត្រី គឺមិនមែនជាលក្ខណៈសាធារណៈ ឬមិនមានឱ្យអ្នកសង្កេតការណ៍ចូលរួម។

**ការចុះមូលដ្ឋាន (ការចុះតាមមណ្ឌល) របស់អ្នកតំណាងរាស្ត្រ និងការចេញលិខិតអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រៈ** នៅក្នុងឆ្នាំទី១ នីតិកាលទី៥នេះ(កញ្ញា២០១៣ ដល់តុលា២០១៤) មានតំណាងរាស្ត្រចំនួន៩៦រូប មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន១២៧៤លើក។ បើប្រៀបធៀបក្នុងរយៈពេលដូចគ្នា នៅឆ្នាំចុងក្រោយនៃនីតិកាលទី៤ ខុមហ្វ្រែលសង្កេតឃើញថា មានការថយចុះយ៉ាងច្រើន ដែលក្នុងរយៈពេលនោះ មានតំណាងរាស្ត្រចំនួន១០៨រូបចុះធ្វើសកម្មភាពបានចំនួន២៧២៩លើក។ មូលហេតុសំខាន់ៗនៃការថតចុះនេះគឺ នៅដើមនីតិកាលទី៥ ក្រុមតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមិនចូលរដ្ឋសភា ហើយសកម្មភាពរបស់ខ្លួនមួយចំនួនក្នុងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ធ្វើសកម្មភាពច្រើននៅរាជធានីភ្នំពេញទាក់ទងទំនាស់នយោបាយ និងម្យ៉ាងទៀតជាឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ដែលតំណាងបានធ្វើសកម្មភាពច្រើនក្នុងការជួបសំណេះសំណាលជាមួយម្ចាស់ឆ្នោត និងពង្រឹងបណ្តាញគណបក្ស។

សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិមានចំនួនប្រហាក់ប្រហែលគ្នា។ បើមើលពីចំនួនចុះមូលដ្ឋានរបស់តំណាងរាស្ត្រសរុបទៅតាមគណបក្ស ខុមហ្វ្រែលសង្កេតឃើញថា ចំនួនអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា ធ្វើសកម្មភាពនៅមូលដ្ឋានច្រើនជាងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ តែបើមើលចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រវិញឃើញថា ចំនួននៃការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ មានចំនួនច្រើនជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។ ក្នុងរយៈពេលនេះ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចុះមូលដ្ឋានចំនួន៦៥៤លើក រីឯតំណាងរាស្ត្រមកពីគណបក្សប្រជាជនចុះមូលដ្ឋានចំនួន៦១០លើក។

ការចេញលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រនៅឆ្នាំទី១ នីតិកាលទី៥នេះ មានតំណាងរាស្ត្រ៧រូប បានចេញលិខិតចំនួន២៥ច្បាប់ ទៅតំណាងរាជរដ្ឋាភិបាល ក្នុងនោះមាន លិខិតក្នុងគោលបំណងអំពាវនាវ/ស្នើចាត់វិធានការចំនួន១២ច្បាប់ លិខិតអន្តរាគមន៍ចំនួន៩ច្បាប់ និងលិខិតកោះហៅរដ្ឋមន្ត្រីមកបំភ្លឺក្នុងរដ្ឋសភាចំនួន៤ច្បាប់។ បើប្រៀបធៀបក្នុងរយៈពេលដូចគ្នាក្នុងនីតិកាលទី៤ គឺមានការកើនឡើង៣៦% ដែលនាពេលនោះមានតំណាងរាស្ត្រចំនួន៨រូបបានចេញលិខិតចំនួន១៦ច្បាប់។

**កំណែទម្រង់រដ្ឋសភាទាក់ទងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភា:** នៅបន្ទាប់ពីបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ៥៥រូប បានសម្រេចចូលរួមក្នុងរដ្ឋសភា នីតិកាលទី៥នេះ គណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា បានព្រមព្រៀងគ្នាធ្វើកំណែទម្រង់រដ្ឋសភា។ កំណែទម្រង់រដ្ឋសភានេះ តាមរយៈកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ បានចែងថា «គណបក្សទាំងពីរឯកភាពគ្នាធ្វើការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីឱ្យស្ថាប័ននេះអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធភាព ក្នុងនោះលើកកំពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និង

លិខិតបទដ្ឋានគតិយុត្តិជាធរមាន។ គណបក្សទាំងពីរឯកភាពគ្នារៀបចំក្បាលម៉ាស៊ីនរដ្ឋសភា ដោយបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា»។

រដ្ឋសភាបានធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា មាត្រា ៦ ថ្មី និងមាត្រា ៤៨ ថ្មី (ពីរ)។ វិសោធនកម្មមាត្រា ៦ ថ្មី បានបញ្ញត្តិដំឡើងចំនួនគណៈកម្មការជំនាញពី៩ ដល់១០ ដែលជាគណៈកម្មការបោសសំអាត ប្រឆាំងអំពើពុករលួយ។ វិសោធនកម្មមាត្រា ៤៨ ថ្មី (ពីរ) បានបង្កើតឱ្យមាន ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សយោបាយ ចំពោះគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនេះមានភារកិច្ចដឹកនាំតំណាងរាស្ត្ររបស់គណបក្ស ដើម្បីធ្វើឱ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅស្របតាមកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស និងធ្វើការសម្របសម្រួលជាមួយថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីធ្វើឱ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅដោយរលូន និងធានាបាននូវផលប្រយោជន៍របស់ជាតិ និងប្រជាពលរដ្ឋ។

វិសោធនកម្ម ក៏បានផ្តល់យោបល់ថា «រដ្ឋសភាត្រូវផ្តល់នូវមធ្យោបាយសមស្រប ដើម្បីឱ្យថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អនៅក្នុងរដ្ឋសភា»។

ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយក្រៅរដ្ឋាភិបាល ដែលមានអាសនៈក្នុងរដ្ឋសភា ចាប់ពី ២៥ (ម្ភៃប្រាំ) ភាគរយឡើងទៅ មានឈ្មោះហៅថា ប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា។ ប្រធានក្រុមមតិភាគតិច ជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ។ ប្រធានក្រុមមតិភាគតិច មានឋានៈស្មើនាយករដ្ឋមន្ត្រី។

ការបង្កើតប្រធានក្រុមភាគតិច អាចចូលរួមលើកកម្ពស់តួនាទីគណបក្សប្រឆាំង ឬគណបក្សនយោបាយក្រៅរដ្ឋាភិបាល និងបង្កើតវប្បធម៌សន្ទនា រវាងថ្នាក់ដឹកគណបក្សនយោបាយដែលអានអាសនៈក្នុងរដ្ឋសភា។

វិសោធនកម្មប្រការ៤៨ ថ្មី(ពីរ) គណបក្សទាំងពីរមិនបានលុបចោលលក្ខខណ្ឌតម្រូវតំណាងរាស្ត្រ១០រូប ក្នុងការបង្កើតក្រុម ដែលចំណុចប៉ះពាល់ដល់ការបញ្ចេញមតិរបស់គណបក្សដែលទទួលអាសនៈតិចជាង១០។

គណបក្សនយោបាយទាំងពីរក៏បានបង្កើតក្រុមការងារកំណែទម្រង់រដ្ឋសភា ហើយកំពុងបន្តការងាររបស់ខ្លួន។

ការចាប់ខ្លួន និងការដោះលែងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ដោយសារមូលហេតុនយោបាយ។

នៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១៤ បេក្ខជនជាប់ឆ្នោតប្រាំពីរ (៧)រូប នៃគណបក្សសង្គ្រោះជាតិរួមមាន លោកស្រី មូរ សុខហួរ លោក ម៉ែន សុថាវិរិន្ទ្រ លោក ហូរ វ៉ាន់ លោក រៀល ខេមរិន្ទ្រ លោក កែវ ភីរម្យ លោក ឡុង រី និង លោក នុត រំដួល ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចាប់ឃុំខ្លួន និងធ្វើការចោទប្រកាន់។ ការចាប់ខ្លួននោះមានចេតនាដើម្បីចាប់បង្ខំឲ្យតំណាងរាស្ត្រគណបក្សប្រឆាំងចូលរួមក្នុងរដ្ឋសភា បន្ទាប់ពីបានជាប់គាំងនយោបាយជាច្រើនខែនៅក្រោយការបោះឆ្នោត ហើយករណីនេះត្រូវទទួលការរិះគន់ជាខ្លាំង និងត្រូវបានមើលឃើញថា ជារឿងនយោបាយ។ ទោះជាយ៉ាងណា អ្នកទាំងនោះត្រូវបានដោះលែងវិញភ្លាមៗ នៅបន្ទាប់ពីកិច្ចចរចាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ប៉ុន្តែតុលាការនៅបន្តនីតិវិធីរបស់ខ្លួន ដោយបានកោះហៅអ្នកទាំងនោះទៅបំភ្លឺនៅតុលាការនៅក្រោយការដោះលែង និងព្រមទាំងមានការចាប់ខ្លួនមន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិជាបន្តបន្ទាប់ទាក់ទងករណីដូចគ្នានេះ

ក្នុងអំឡុងពេលចរចារនៃការអនុវត្តកំណែទម្រង់ការបោះឆ្នោត និងរដ្ឋសភា។

**អនុសាសន៍សំខាន់ៗ៖**

- ដើម្បីដោះស្រាយទំនាស់នៃការបកស្រាយ នៃការបង្កើតរដ្ឋសភា បី(០៣)ថ្ងៃក្រោយពេលការប្រកាសលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីសមាជិកតំណាងរាស្ត្រដែលមានយ៉ាងតិច១២០រូបថ្វាយព្រះមហាក្សត្រ។ (វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)
- ដើម្បីតម្លាភាពនៃការផ្លាស់ប្តូរតំណាងរាស្ត្រ, សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយសារសាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ហើយបញ្ជាក់ពីមូលហេតុ និងផ្សព្វផ្សាយជាសាធារណៈ។ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដែលមានការសម្រេចជាលាយលក្ខណ៍អក្សរ តែមិនមែនមូលហេតុដោយសារការបញ្ចេញមតិខុសឆ្គង។ (មាត្រា ១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)
- គណៈកម្មការជំនាញនីមួយៗ នៃរដ្ឋសភាត្រូវកំណត់ពេល ០១ (មួយ) ថ្ងៃ ក្នុង ០១ (មួយ) សប្តាហ៍ ដើម្បីធ្វើសវនាការសាធារណៈ ជជែកដេញដោល ដោយកោះហៅជនពាក់ព័ន្ធមកបំភ្លឺលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ និងការអនុវត្តច្បាប់ជាធរមាន។ ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះមិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។
- កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន និងជាសាធារណៈ លើកលែងតែជាកំណត់ហេតុ និងឯកសារទាំងឡាយណាដែលសំរេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ថាអាចប៉ះពាល់ដល់សន្តិសុខជាតិ។ (ប្រការ១៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។ អគ្គលេខាធិការដ្ឋានត្រូវរៀបចំឲ្យមានបទបញ្ជារដ្ឋបាល ដើម្បីធានាសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈរបស់រដ្ឋសភា។(ប្រការថ្មី បញ្ចូលទៅក្នុងជំពូកទី ៤)។
- ចម្លើយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ត្រូវធ្វើឡើងក្នុងរយៈពេល(១៥)ដប់ប្រាំថ្ងៃបន្ទាប់ពីទទួលបានសំណួរ។ ចំពោះចម្លើយផ្ទាល់មាត់តំណាងរាស្ត្រដាក់សំណួរ និងរាជរដ្ឋាភិបាលមានសិទ្ធិទទួលបានពេលវេលាស្មើគ្នាក្នុងការជជែកដេញដោល។ ចំពោះចម្លើយជាលាយលក្ខណ៍អក្សរ តំណាងរាស្ត្រដាក់សំណួរមានសិទ្ធិឆ្លើយតបក្នុងរដ្ឋសភា ក្នុងរយៈពេលស្មើគ្នានឹងការអានចម្លើយជាលាយលក្ខណ៍អក្សររបស់រាជរដ្ឋាភិបាល។
- វេទិកានៃការជជែកដេញដោល គួរមានការអង្គុយ និងការឈរទល់មុខគ្នារវាងនាយករដ្ឋមន្ត្រី និងប្រធានក្រុមភាគតិច។
- លុបចោលសារាចរណែនាំស្តីពីបែបបទការងារ ស្តីពីគណៈកម្មការនានានៃរដ្ឋសភា ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៤ ចេញដោយប្រធានរដ្ឋសភា។

**សម្រាប់ព័ត៌មានបន្ថែម៖**

| ឈ្មោះ | អង្គការ | លេខទូរស័ព្ទ |
|---|---|---|
| • លោក គល់ បញ្ញា | ខុមហ្វ្រែល | ០១២ ៩៤២ ០១៧ |
| • លោក កន សាវ៉ាង្ស | ខុមហ្វ្រែល | ០១១ ៨៨៤ ៨៤០ |
| • លោក ស៊ិន ទិត្យសីហា | ខុមហ្វ្រែល | ០១២ ២៥២ ៦៦១ |